THE SCHOOL DISTRICT OF PHILADELPHIA

**ការិយាល័យប្រាស្រ័យទាក់ទង**
Suite 301
440 North Broad Street
Philadelphia, PA 19130

ថ្ងៃទី 1 ខែតុលា ឆ្នាំ 2021

សូមគោរពសមាជិកគ្រួសារ School District of Philadelphia

ដោយយើងចាប់ផ្តើមខែបន្ទាប់នៃការចូលរៀននេះ យើងចង់ចែករំលែកបច្ចុប្បន្នភាពអំពីបញ្ហាប្រឈមនឹងកង្វះខាតអ្នកបើកបរដែលយើងបន្តជួបប្រទះ និងវិធានការបន្ថែមទៀតដែលយើងនឹងអនុវត្តដើម្បីគាំទ្រដល់សុវត្ថិភាពសាលារៀន។

**<u>ការប្រមូលសំរាមនៅសាលារៀន</u>**

ដូចដែលអ្នកដឹងហើយ កង្វះខាតអ្នកបើកបរបានប៉ះពាល់ដល់គុណភាពសេវាកម្មរបស់ក្រុមហ៊ុនផ្តល់សេវាកម្មប្រមូលសំរាមដែលទទួលខុសត្រូវចំពោះការយកសំរាមឲ្យអស់ពីធុងដាក់សំរាមធំ ដែលបណ្តាលឲ្យមានសំរាមហូរហៀរច្រើនគួរឲ្យកត់សម្គាល់នៅសាលារៀនជាច្រើនក្នុងចំណោមសាលារៀនរបស់យើង។ បន្ថែមពីលើការធ្វើការជាមួយទីក្រុង ដើម្បីធានាបានលទ្ធភាពមានធុងសំរាមធំប្រើដោយការយកយានជំនិះដែលចតដោយខុសច្បាប់ចេញ និងប្រើប្រាស់បុគ្គលិកផ្នែកថែទាំរបស់យើង ដើម្បីស្វែងរកទីតាំងថ្មីជាបណ្តោះអាសន្នសម្រាប់សំរាមដែលច្រើនហួសទៅកាន់ធុងសំរាមធំបន្ថែមដែលត្រូវបានដាក់នៅទូទាំងទីក្រុង ឥឡូវនេះ យើងបានជួលក្រុមហ៊ុនផ្តល់សេវាកម្មចំនួនប្រាំបន្ថែមទៀតដែលផ្តោតលើការរក្សាតំបន់នៅជុំវិញធុងសំរាមធំកុំឲ្យមានការរាយប៉ាយ។ ហើយយើងមានក្តីសោមនស្សរីករាយនឹងរាយការណ៍ថា ក្រុមហ៊ុនផ្តល់សេវាកម្មប្រមូលសំរាមដើមរបស់យើងរំពឹងថានឹងត្រលប់មកផ្តល់សេវាកម្មពេញលេញវិញនៅត្រឹមថ្ងៃទី 15 ខែតុលា ដើម្បីគាំទ្របន្ថែមទៀតដល់កិច្ចប្រឹងប្រែងសម្អាតរបស់យើង។ យើងនឹងបន្តធ្វើការដើម្បីកំណត់ក្រុមហ៊ុនផ្តល់សេវាកម្មប្រមូលសំរាមបន្ថែមទៀត ដើម្បីជួយបន្ថយកាត់បន្ថយហានិភ័យនៃការបោះចោលសំរាមឲ្យនៅសល់តិចជាអប្បបរមានាពេលអនាគត និងគាំទ្រដល់សាលារៀនដែលស្អាត និងប្រកបដោយសុខភាពល្អ។

**<u>ការដឹកជញ្ជូនសិស្ស</u>**

កង្វះខាតអ្នកបើកបរបន្តរំខានខ្លាំងដល់សេវាកម្មដឹកជញ្ជូនសិស្សរបស់យើង ក៏ដូចជាសាលារៀនទាំងឡាយ និងឧស្សាហកម្មដទៃទៀតនៅទូទាំងប្រទេស។ ជាអកុសល វាច្បាស់ណាស់ថានេះមិនគ្រាន់តែជាបញ្ហារយៈពេលខ្លីនោះទេ ប៉ុន្តែជាបញ្ហារយៈពេលវែងដែលឆាប់ៗនេះនឹងត្រូវការឲ្យយើងបង្កើតជម្រើសដ៏ពិបាកមួយចំនួន ដូច្នេះហើយយើងអាចផ្តល់សេវាកម្មដ៏គួរជាទីទុកចិត្តបានដល់សិស្សដែលយើងអាចបម្រើជូនបានដោយធនធានដែលមានកំណត់របស់យើង។ ទន្ទឹមនឹងនេះ យើងកំពុងតែបន្តស្វែងរកជម្រើសដែលអាចមានទាំងអស់។ ប្រសិនបើអ្នកអាចចូលរួមក្នុងជម្រើសនេះបាន សូមពិចារណាចុះឈ្មោះនៅក្នុង [កម្មវិធីអត្រាតម្លៃស្មើសម្រាប់ឪពុកម្តាយ] របស់យើងដែលនឹងបង់ $150-$300 ក្នុងមួយខែទៅដល់ក្រុមគ្រួសារដែលមានសិទ្ធិដែលជ្រើសរើសដឹកជញ្ជូនកូនៗរបស់ពួកគេទៅកាន់ និងមកពីសាលារៀន។ ឪពុកម្តាយដែលត្រូវបានចុះឈ្មោះរួចហើយនៅក្នុងកម្មវិធីនេះអាចរំពឹងថានឹងទទួលបានការបង់ទូទាត់លើកដំបូងរបស់ពួកគេនៅក្នុងខែវិច្ឆិកា។

**<u>សុខភាព និងសុវត្ថិភាព</u>**

**ការិយាល័យប្រាស្រ័យទាក់ទង**
Suite 301
440 North Broad Street
Philadelphia, PA 19130

ថ្ងៃទី 30 ខែកញ្ញា ជាថ្ងៃដល់កំណត់សម្រាប់អាណត្តិវ៉ាក់សាំង COVID-19 របស់ក្រុមប្រឹក្សាសាលារៀនសម្រាប់បុគ្គលិកមណ្ឌល។ ចាប់ពីថ្ងៃចន្ទ ទី 4 ខែតុលា បុគ្គលិកដែលបានចាក់វ៉ាក់សាំងពេញលេញនឹងបន្តធ្វើតេស្តមួយដងក្នុងមួយសប្តាហ៍ ខណៈដែលអ្នកដែលបានចាក់វ៉ាក់សាំងមិនទាន់ពេញលេញនឹងត្រូវបានតម្រូវឲ្យធ្វើតេស្តពីរដងក្នុងមួយសប្តាហ៍។

អាណត្តិវ៉ាក់សាំង និងការធ្វើតេស្តដែលបានពង្រីកសម្រាប់បុគ្គលិកដែលមិនបានចាក់វ៉ាក់សាំងពេញលេញគឺគ្រាន់តែជាស្រទាប់ពីរនៃ ពហុស្រទាប់នៃសុវត្ថិភាព ដែលមានដាក់ឲ្យប្រើប៉ុណ្ណោះ ដើម្បីគាំទ្រដល់សុខុមាលភាពរបស់មនុស្សគ្រប់គ្នានៅសាលារៀន និងការិយាល័យរបស់យើង។ អ្នកអាចជួយគាំទ្រដល់សាលារៀនដែលប្រកបដោយសុខភាពល្អបានដោយៈ

- ក្រើនរំលឹកកូនៗរបស់អ្នកឲ្យពាក់ម៉ាស និងលាងដៃពួកគេឲ្យបានញឹកញាប់។
- ឲ្យកូនរបស់អ្នកនៅផ្ទះ ប្រសិនបើពួកគេឈឺ ឬបានប៉ះពាល់ជាមួយនរណាម្នាក់ដែលធ្វើតេស្តរកឃើញវិជ្ជមាន COVID-19 ក្នុងពេលថ្មីៗនេះ។
- បញ្ជូនភស្តុតាងនៃការចាក់វ៉ាក់សាំងរបស់កូនអ្នកទៅកាន់ការិយាល័យសេវាកម្មសុខភាពសិស្សរបស់យើងតាមគេហទំព័រ 5vax@philasd.org ដើម្បីជួយយើងឲ្យកំណត់បានកាន់តែប្រសើរឡើងថានរណាអាចនឹងត្រូវតែធ្វើចត្តាឡីស័កឬក៏អត់នៅពេលអនាគត។
- ហើយ សូមចាក់វ៉ាក់សាំង ប្រសិនបើអ្នក ឬកូនរបស់អ្នក មានអាយុអាយុចាប់ពី 12 ឆ្នាំ ឡើងទៅមិនទាន់បានចាក់វ៉ាក់សាំង។ អ្នកអាចស្វែងរកព័ត៌មានបន្ថែមអំពីវ៉ាក់សាំង និងទីកន្លែងដែលត្រូវទៅចាក់វ៉ាក់សាំងតាមគេហទំព័រ www.phila.gov និងតាមគេហទំព័រ www.vaccines.gov។

យើងនឹងចែករំលែកបច្ចុប្បន្នភាពថែមទៀតនៅពេលឆាប់ៗនេះ។ សូមអរគុណសម្រាប់ភាពជាដៃគូដ៏អស្ចារ្យនៅក្នុងការអប់រំរបស់កូនអ្នក។

ដោយក្តីរាប់អានដ៏ស្មោះស្ម័គ្រ

*School District of Philadelphia*
*ការិយាល័យប្រាស្រ័យទាក់ទង*